**ឯកសារស្រាវជ្រាវសង្ខេប**

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

# ភេរវកម្ម៖ តម្រូវការក្នុងការលើកកម្ពស់កិច្ចសហ-ប្រតិបត្តិការជាសកលប្រឆាំងនឹងការគម្រាមកំហែងទៅលើលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិបុគ្គល

**អ្នកស្រាវជ្រាវ៖** លោក **ខាំ វ៉ាន់ដា**

លោក **ថេង ណាន**

ខែតុលា ឆ្នាំ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)គឺជាស្ថាប័នឯករាជ្យមួយដែល ផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភាដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯក-សារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពី ទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពី វិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា

សេចក្តីផ្តើម ........................................ 1

កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងភេរវកម្មជាសកលនិងថ្នាក់តំបន់ ........................................ 1

ការចូលរួមចំណែករបស់កម្ពុជាក្នុងកិច្ចសហប្រតិបត្តិការប្រឆាំងភេរវកម្មជាសកលនិងថ្នាក់តំបន់ និងសកម្មភាពសំខាន់ៗក្នុងការប្រឆាំងភេរវកម្មនៅកម្ពុជា ........................................ 3

ការចូលរួមចំណែករបស់កម្ពុជាក្នុងកិច្ចសហប្រតិបត្តិការជាសកលនិងថ្នាក់តំបន់ ........................................ 3

សកម្មភាពសំខាន់ៗក្នុងការប្រយុទ្ធប្រឆាំងភេរវកម្មនៅកម្ពុជា ........................................ 4

សេចក្តីសន្និដ្ឋាន ........................................ 5

គន្ថនិទ្ទេស ........................................ 7

# សេចក្ដីផ្ដើម

ភេរវកម្មបានចាប់ផ្ដើមស្ថិតនៅក្នុងរបៀបវារៈរបស់អន្តរជាតិចាប់តាំងពីឆ្នាំ១៩៣៤ ខណៈដែលសម្ព័ន្ធប្រជាជាតិ (League of Nations) បានចាប់ផ្ដើមជំហានដំបូងដើម្បីពិភាក្សាទៅលើសេចក្ដីព្រៀងអនុសញ្ញាសម្រាប់កិច្ចការពារនិងការដាក់ទណ្ឌកម្មលើភេរវកម្ម។[1] ក្រោយពីការវាយប្រហាររបស់ភេរវករនៅសហរដ្ឋអាមេរិក នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ភេរវកម្មបានក្លាយទៅជាបញ្ហាដែលគួរបារម្ភណ៍ដ៏សំខាន់សម្រាប់សហគមន៍អន្តរជាតិ។[2] ភេរវកម្មបានចាប់ផ្ដើមរាលដាលក្នុងរយៈពេលពីរ បីឆ្នាំចុងក្រោយនេះនៅក្នុងប្រទេស ស៊ីរី អ៊ីរ៉ាក់ លីប៊ី ម៉ាលី នីហ្សេរីយ៉ា សូម៉ាលី យ៉េមែន និងថ្មីៗនេះ នៅក្នុងប្រទេសបារាំង និងដាណឺម៉ាក។[3] ភេរវកម្មគឺជាបញ្ហាសកលលោកទាំងមូល ដែលតម្រូវឲ្យជាតិនីមួយៗពង្រឹងកិច្ចសហប្រតិបត្តិការទាំងក្នុងតំបន់ និងអន្តរជាតិដើម្បីប្រឆាំងនឹងការរាលដាលរបស់ភេរវកម្ម។[4] ការប្រឆាំងភេរវកម្មប្រហែលជាមិនអាចដោះស្រាយបានដោយប្រសិទ្ធិភាពនិងជោគជ័យបានទេ ប្រសិនបើពុំមានកិច្ចសហប្រតិបត្តិការទាំងក្នុងតំបន់និងអន្តរជាតិ។ ដូច្នេះហើយ ជាការសំខាន់ណាស់សម្រាប់ប្រទេសនីមួយៗដែលត្រូវតែសហការគ្នា។

ឯកសារស្រាវជ្រាវសង្ខេបនេះ នឹងសិក្សាដោយសង្ខេបទៅលើការចូលរួមចំណែករបស់កម្ពុជា ក្នុងការប្រឆាំងភេរវកម្មនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ លើសពីនេះទៀត ឯកសារនេះនឹងផ្ដល់ដោយសង្ខេបអំពីកិច្ចសហប្រតិបត្តិការជាសកលក្នុងការប្រយុទ្ធប្រឆាំងភេរវកម្ម។

# កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងភេរវកម្មជាសកលនិងថ្នាក់តំបន់

ដើម្បីប្រយុទ្ធប្រឆាំងភេរវកម្ម អង្គការសហប្រជាជាតិបានផ្ដួចផ្ដើមបង្កើតយុទ្ធសាស្ត្រជាសកលប្រឆាំងភេរវកម្ម (the UN Global Counter-Terrorism Strategy-UN-GCTS) ដែលអនុម័តដោយរដ្ឋជាសមាជិកចំនួន ១៩២ នៅខែ កញ្ញា ឆ្នាំ ២០០៦។[5] នេះហាក់ដូចជាបង្ហាញថាមានការឯកភាពគ្នាក្នុងចំណោមសហគមន៍អន្តរជាតិដើម្បីប្រឆាំងនឹងការគម្រាមកំហែងរបស់ភេរវកម្ម។ UN-GCTS បានបង្ហាញនូវផែនការសកម្មភាព

[1] UNACT. “International Legal Instruments.” Accessed on September 02, 2015. URL: http://www.un.org/en/terrorism/instruments.shtml
[2] Chheang Vannarith, and Chap Sotharith. "The Fight against International Terrorism: Cambodian Perspective." Working Paper No. 23, Phnom Penh, 2008.
[3] Marcel Furstenau. “Intelligence director warns of global spread of terrorism.” *DW*, February 25, 2015. Accessed on 26 August, 2015. URL: http://www.dw.com/en/intelligence-director-warns-of-global-spread-of-terrorism/a-18281998
[4] NATO. “Countering terrorism.” September 01, 2015. Accessed on 09 September, 2015. URL: http://www.nato.int/cps/en/natohq/topics_77646.htm
[5] Xiaohui, WU. "A Regional-Global Paradigm for Implementing the United Nations Global Counter-Terrorism Strategy." Defence Against Terrorism Review 2, no. 2 (2009): 83-98.

ដើម្បីឲ្យរដ្ឋជាសមាជិកអនុវត្តយុទ្ធសាស្ត្រនោះ ហើយក៏បានបញ្ជាក់អំពីតម្រូវការឲ្យមានការខិតខំប្រឹងប្រែងរួមសម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ និងសកលលោក។[6] UN-GCTS បានដាក់ចេញនូវវិធានការណ៍គន្លឹះចំនួនបួនសម្រាប់ប្រយុទ្ធប្រឆាំងភេរវកម្ម៖ *១) ដោះស្រាយស្ថានភាពដែលបណ្តាលឲ្យរាលដាលភេរវកម្ម ២) ការពារនិងបង្ក្រាបភេរវកម្ម ៣) កសាងសមត្ថភាពរបស់រដ្ឋដើម្បីការពារនិងបង្ក្រាបភេរវកម្ម និងពង្រឹងតួនាទីរបស់ប្រព័ន្ធអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងបញ្ហានេះ និង៤) ធានាឲ្យមានការគោរពសិទ្ធិមនុស្សជាសកល និងនីតិរដ្ឋជាមូលដ្ឋានគ្រឹះក្នុងការប្រយុទ្ធប្រឆាំងភេរវកម្ម។*[7]

លើសពីនេះទៀត នៅឆ្នាំ ២០០៥ អគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្កើត ក្រុមការងារប្រតិបត្តិការប្រឆាំងភេរវកម្ម (CTICF) ដែលគាំទ្រ ដោយមហាសន្និបាត តាមរយៈយុទ្ធសាស្ត្រជាសកលប្រឆាំង ភេរវកម្មរបស់អង្គការសហប្រជាជាតិ (UN-GCTS) ដើម្បីធានាការសម្របសម្រួលនិងភាពស៊ីសង្វាក់នៃសកម្មភាពប្រឆាំងភេរវកម្មរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ។ CTICF ក៏បានផ្តល់នូវការគាំទ្រផ្នែកគោលនយោបាយ និងបច្ចេកទេស ដោយរួមទាំងការចែករំលែកចំណេះដឹងស៊ីជម្រៅអំពី UN-GCTS ដល់រដ្ឋជាសមាជិកផងដែរ។ ក្រុមការងារនេះចូលរួមដោយស្ថាប័នអន្តរជាតិចំនួន៣១ (ដូចជា៖ អង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ "អាំងទែប៉ូល" ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្ម និងគ្រឿងញៀន "UNODC" អង្គការសម្រាប់ប្រឆាំងអាវុធគីមី "OPCW" ជាដើម)[8] ដែលចូលរួមចំណែកជាមួយក្រុមការងារប្រឆាំងភេរវកម្មរបស់អង្គការសហប្រជាជាតិដោយផ្អែកលើអាណត្តិរបស់ខ្លួន។[9]

នៅខែមករា ឆ្នាំ២០០៧ អនុសញ្ញា ស្តីពីការប្រឆាំងភេរវកម្មអាស៊ាន (ACCT) ត្រូវបានរៀបចំឡើង ហើយត្រូវបានរដ្ឋដែលជាសមាជិកអាស៊ានទាំងដប់បានផ្តល់សច្ចាប័នរួចហើយ។[10] អនុសញ្ញា ស្តីពីការប្រឆាំងភេរវកម្មជាសមិទ្ធិផលដ៏សំខាន់របស់អាស៊ានក្នុងកិច្ចខិតខំប្រយុទ្ធប្រឆាំងភេរវកម្ម ព្រោះអនុសញ្ញានេះប្រើសម្រាប់ជាក្របខ័ណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការតំបន់ក្នុងការប្រឆាំង ការពារ និងបង្ក្រាបភេរវកម្ម និងពង្រឹងកិច្ចសហ-ប្រតិបត្តិការប្រឆាំងភេរវកម្ម។[11] អនុសញ្ញានេះជួយជម្រុញឲ្យមានយុទ្ធសាស្ត្រតំបន់ស្របទៅនឹងយុទ្ធសាស្ត្រប្រឆាំងភេរវកម្មសកល។ អនុសញ្ញានេះក៏បានបញ្ចូលនូវផ្នែកទាំងឡាយសម្រាប់សហប្រតិបត្តិការផងដែរ (ដូចជា៖ ក) ពង្រឹងការផ្លាស់ប្តូរព័ត៌មានសម្ងាត់និងចែករំលែកព័ត៌មាន ខ) កិច្ចការពារការចល័តរបស់ភេរវករ

---

[6] ដូចខាងលើ ទំព័រ ៨៦ United Nations. "The United Nations Global Counter-Terrorism Strategy." 2006. Accessed on 26 August, 2015. URL: http://www.un.org/en/terrorism/strategy-counter-terrorism.shtml

[7] United Nations. "The United Nations Global Counter-Terrorism Strategy." 2006. Accessed on 26 August, 2015. URL: http://www.un.org/en/terrorism/strategy-counter-terrorism.shtml

[8] អាំងទែប៉ូលក៏ជាសមាជិកនៃកម្លាំងប្រតិបត្តិការប្រឆាំងភេរវកម្មនេះផងដែរ។ សម្រាប់ព័ត៌មានបន្ថែមអំពីស្ថាប័នទាំងនេះ សូមចូលមើលក្នុងតំណភ្ជាប់នេះ៖ http://www.un.org/en/terrorism/ctitf/entities.shtml

[9] CTITF. Counter-Terrorism Implementation Task Force. Accessed on 01 September, 2015. URL: http://www.un.org/en/terrorism/ctitf/index.shtml

[10] http://www.asean.org/news/asean-secretariat-news/item/asean-convention-on-counter-terrorism-completes-ratification-process (Accessed on 11 September 2015)

[11] ASEAN. "ASEAN Convention on Counter Terrorism." 2014. Accessed on 07 September, 2015. URL: http://www.asean.org/news/item/asean-convention-on-counter-terrorism

ឬ ក្រុមភេរវករ ដោយការត្រួតពិនិត្យព្រំដែនប្រកបដោយប្រសិទ្ធិភាព តាមរយៈវិធានការណ៍ទប់ស្កាត់ ការប្រើប្រាស់ឯកសារសម្គាល់អត្តសញ្ញាណ និងឯកសារធ្វើដំណើរក្លែងក្លាយជាដើម) សម្រាប់រដ្ឋជាសមាជិកអាស៊ានក្នុងការប្រឆាំងភេរវកម្ម។[12]

# ការចូលរួមចំណែករបស់កម្ពុជាក្នុងកិច្ចសហប្រតិបត្តិការប្រឆាំងភេរវកម្មជាសកលនិងថ្នាក់តំបន់ និងសកម្មភាពសំខាន់ៗក្នុងការប្រឆាំងភេរវកម្មនៅកម្ពុជា

## ការចូលរួមចំណែករបស់កម្ពុជាក្នុងកិច្ចសហប្រតិបត្តិការជាសកលនិងថ្នាក់តំបន់

កិច្ចសហប្រតិបត្តិការជាសកល និងថ្នាក់តំបន់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រឆាំងភេរវកម្ម។ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការនៅថ្នាក់តំបន់ កម្ពុជាបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាដែលពាក់ព័ន្ធ និងពិធីសាររបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងភេរវកម្ម។[13] កម្ពុជាក៏បានទទួលធ្វើជាម្ចាស់ផ្ទះក្នុងការហ្វឹកហ្វឺនការថែរក្សាសន្តិភាពពហុជាតិ ដែលមានលក្ខណៈទ្រង់ទ្រាយធំផងដែរ ដែលជាផ្នែកមួយនៃកិច្ចផ្តួចផ្តើមប្រតិបត្តិការសន្តិភាពសកលរបស់អាមេរិកកាំង និងអង្គការសហប្រជាជាតិឆ្នាំ២០១០ (U.S.-UN 2010 Global Peace Operations Initiative) នៅខែ កក្កដា ឆ្នាំ ២០១០។[14] សមយុទ្ធយោធានេះត្រូវបានធ្វើឡើងដោយមានការចូលរួមពីយោធាប្រមាណជាង ៧០០នាក់ មកពី២៤ប្រទេស។[15] ការទទួលធ្វើជាម្ចាស់ផ្ទះក្នុងការធ្វើសមយុទ្ធនេះបានបង្ហាញ ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការសកលសម្រាប់សន្តិភាព និងសន្តិសុខ និងប្រឆាំងភេរវកម្មអន្តរជាតិ។ លើសពីនេះទៀត សេចក្តីថ្លែងការណ៍របស់លោកបណ្ឌិត ជា កុសល ដែលជាឯកអគ្គរាជទូត និងតំណាងអចិន្ត្រៃនៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហ-ប្រជាជាតិ នៅថ្ងៃទី៨ ខែ តុលា ឆ្នាំ២០១២ បានបង្ហាញអំពីការគាំទ្រពេញលេញទៅលើសេចក្តីសម្រេចដែល

[12] ដូចខាងលើ. មាត្រា៦

[13] Sea Kosal. Measures to Eliminate International Terrorism. 2012. Accessed on 07 September, 2015. URL: http://papersmart.unmeetings.org/media/643762/Cambodia_Sea%20Kosal_statement.pdf; អនុសញ្ញាដែលពាក់ព័ន្ធរួមទាំង៖ (i) អនុសញ្ញាអន្តរជាតិដើម្បីបង្ក្រាបការបំផ្ទុះគ្រាប់បែកភេរវកម្មឆ្នាំ ១៩៩៧ (ii) អនុសញ្ញាអន្តរជាតិដើម្បីបង្ក្រាបហិរញ្ញប្បទានភេរវកម្ម ឆ្នាំ១៩៩៩។ សូមមើល តំណភ្ជាប់នេះ សម្រាប់ព័ត៌មានបន្ថែម៖ https://treaties.un.org/Pages/DB.aspx?path=DB/studies/page2_en.xml&menu=MTDSG

[14] ដូចខាងលើ៖ កិច្ចផ្តួចផ្តើមប្រតិបត្តិការសន្តិភាពសកល Global Peace Operations Initiative (GPIO) គឺជាកម្មវិធីបណ្តុះបណ្តាលការថែរក្សាសន្តិភាពរបស់អាមេរិកកាំងនិងអង្គការសហប្រជាជាតិដើម្បីពង្រឹងសន្តិភាពនិងសន្តិសុខ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល តាមតំណភ្ជាប់នេះ៖ http://www.embassyofcambodia.org.nz/July302010/July302010.htm.

[15] ប្រទេសទាំងនោះ មានដូចជា៖ អូស្ត្រាលី បង់ក្លាដែស ប៊្រុយណេ កម្ពុជា ចិន អង់គ្លេស បារាំង អាឡឺម៉ង់ ឥណ្ឌា អ៊ិនឌូនេស៊ី ជប៉ុន ឡាវ ម៉ាឡេស៊ី ម៉ុងហ្គូលី ណេប៉ាល់ ញ៉ូហ្ស៊ីឡែន ហ្វីលីពីន រុស្ស៊ី កូរ៉េខាងត្បូង ស៊ីងហាក់បុរី ថៃឡង់ តុងហ្គា សហរដ្ឋអាមេរិក និងវៀតណាម។ សូមមើលតំណភ្ជាប់នេះ៖http://www.embassyofcambodia.org.nz/July302010/July302010.htm

បានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ ស្តីពីការពិនិត្យទៅលើយុទ្ធសាស្ត្រប្រឆាំងភេរវកម្ម របស់អង្គការសហប្រជាជាតិ (Global Counter-Terrorism Strategy Review) នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១២។[16] សេចក្តីសម្រេចនេះបានបញ្ជាក់ជាថ្មីអំពីការចាំបាច់ក្នុងការដោះស្រាយស្ថានភាពដែលនាំឲ្យមានការរាលដាលនៃភេរវកម្ម។ សេចក្តីសម្រេចនេះក៏បានស្នើរដ្ឋជាសមាជិកនិងស្ថាប័នទាំងឡាយរបស់អង្គការសហប្រជាជាតិដែលគាំទ្រកិច្ចខិតខំប្រឹងប្រែងក្នុងការប្រឆាំងភេរវកម្ម ឲ្យបន្តសម្របសម្រួលក្នុងការ ការពារសិទ្ធិមនុស្ស សេរីភាពមូលដ្ឋាន និងនីតិរដ្ឋ ខណៈដែលប្រយុទ្ធប្រឆាំងនឹងភេរវកម្ម។[17]

ដើម្បីចូលរួមចំណែកក្នុងកិច្ចសហប្រតិបត្តិការតំបន់ក្នុងការប្រឆាំងភេរវកម្ម នៅខែមិថុនា ឆ្នាំ២០១០ កម្ពុជាបានក្លាយជាសមាជិកអាស៊ានទី៤ ដែលបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងភេរវ-កម្ម។[18] បន្ថែមពីនេះទៀត នៅខែកញ្ញា ឆ្នាំ២០១០ គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម (NCTC) បានទទួលក្រុមការងារសន្តិសុខតំបន់ប៉ាស៊ីហ្វិកដែលមានអ្នកចូលរួមពីតំណាងប្រទេសអាស៊ាន។ ព្រឹត្តិការណ៍នេះត្រូវបានប្រើជាវេទិការមួយដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ក្នុងការប្រឆាំងភេរវកម្ម។[19]

## សកម្មភាពសំខាន់ៗក្នុងការប្រយុទ្ធប្រឆាំងភេរវកម្មនៅកម្ពុជា

នៅក្នុងឆ្នាំ ២០០៧ ប្រទេសកម្ពុជាបានអនុម័តច្បាប់សំខាន់ៗចំនួនពីរ ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម៖ (១) ច្បាប់ ស្តីពីការប្រឆាំងនឹងភេរវកម្ម និង (២) ច្បាប់ ស្តីពីការប្រឆាំងការលាងសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។[20] លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតស្ថាប័នមួយចំនួនដើម្បីប្រយុទ្ធប្រឆាំងភេរវកម្មនៅក្នុងប្រទេសកម្ពុជារួមមាន៖ (១) គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម (២) អាជ្ញាធរជាតិសម្រាប់បង្កាការប្រើប្រាស់សារធាតុគីមី នុយក្លេអែរ ជីវសាស្ត្រ និងគ្រឿងផ្ទុះវិទ្យុសកម្ម (៣) គណៈកម្មាធិការជាតិសម្រាប់កែទម្រង់លើការត្រួតពិនិត្យអាវុធ និង (៤) គណៈកម្មាធិការជាតិសម្រាប់ សន្តិសុខតាមសមុទ្រ។[21]

បន្ថែមលើសកម្មភាពទាំងនេះ នៅក្នុងឆ្នាំ ២០១៣ ប៉ូលីសប្រឆាំងភេរវកម្មកម្ពុជា ដោយមានការគាំទ្រពីការិយាល័យអង្គការសហប្រជាជាតិ ប្រឆាំងឧក្រិដ្ឋកម្ម និងគ្រឿងញៀន (UNODC) បានរៀបចំសិក្ខាសាលាដែលមានរយៈពេលពីរសប្តាហ៍ ដែលចែកចេញជាបីដំណាក់កាល[22] រួមមាន៖ ការពង្រឹងសមត្ថភាពសម្រាប់

---

[16] Sea Kosal. Measures to Eliminate International Terrorism. 2012.
[17] United Nations. "The United Nations Global Counter-Terrorism Strategy Review." 2012. Accessed on 02 September, 2015. URL: http://www.un.org/en/ga/search/view_doc.asp?symbol=A/RES/66/282
[18] U.S. Department of State. "Country Reports: East Asia and Pacific Overview." 2010. Accessed on 02 September, 2015. URL: http://www.state.gov/j/ct/rls/crt/2010/170255.htm
[19] U.S. Department of State. "Country Reports: East Asia and Pacific Overview." 2010.
[20] Ibid.
[21] Sea Kosal. Measures to Eliminate International Terrorism. 2012.
[22] ប្រធានបទរបស់សិក្ខាសាលាទាំងបីដំណាក់កាលរួមមាន៖ (១) បច្ចេកទេសស៊ើបអង្កេតអន្តរជាតិនានាក្នុងកំរិតមូលដ្ឋាន ដូចជាការបង្កើតព័ត៌មានសំងាត់ផ្នែកហិរញ្ញវត្ថុពីប្រភពព័ត៌មានបើកទូលាយផ្សេងៗ ប្រមូល និងស្វែងរកឯកសារហិរញ្ញវត្ថុនានា និងការរត់ពន្ធរូបិយប័ណ្ណដើម្បីផ្តល់ហិរញ្ញប្បទានភេរវកម្ម (២) បច្ចេកទេសស៊ើបអង្កេតកំរិតខ្ពស់នានា ការបង្កើតព័ត៌មានសំងាត់ផ្នែក ហិរញ្ញវត្ថុពី

អ្នកស៊ើបអង្កេត និងបណ្តុះបណ្តាលគ្រូបង្វឹកប៉ូលីសក្នុងស្រុកដើម្បីប្រឆាំងការផ្តល់ហិរញ្ញប្បទានភេរវកម្ម។[23] ជាលទ្ធផល មន្ត្រីប៉ូលីសប្រឆាំងភេរវកម្មកម្ពុជាចំនួន ៦០ រូប ទទួលបានការបណ្តុះបណ្តាលនូវបច្ចេកទេសស៊ើបអង្កេតកំរិតមូលដ្ឋាននិងកំរិតខ្ពស់ពាក់ព័ន្ធនឹងការលាងសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។[24] លើសពីនេះទៀត ប្រទេសកម្ពុជា បានប្រើប្រាស់ប្រព័ន្ធវាយតម្លៃ និងប្រៀបធៀបការកំណត់អត្តសញ្ញាណបុគ្គលប្រកប ដោយសុវត្ថិភាព (the Personal Identification Secure Comparison and Evaluation System "PISCES")[25] ដែលផ្តល់ដោយសហរដ្ឋអាមេរិក ដើម្បីត្រួតពិនិត្យអ្នកដំណើរនៅតាមច្រកចេញ-ចូលនៅតាមព្រលានយន្តហោះអន្តរជាតិនានា និងនៅតាមច្រកព្រំដែនផ្លូវគោកមួយចំនួន។[26] សកម្មភាពទាំងនេះ បានចូលរួមចំណែកមួយផ្នែកក្នុងការធានានូវសន្តិសុខក្នុងប្រទេសផងដែរ។

# សេចក្តីសន្និដ្ឋាន

តាមរយៈការដាក់ចេញនូវឧបករណ៍ផ្នែកគតិយុត្តិមួយចំនួននិងការរៀបចំនូវស្ថាប័ននានា រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ក្នុងកិច្ចសហប្រតិបត្តិការ ជាសាកល និងតំបន់ដើម្បីប្រឆាំងនឹងភេរវកម្ម។ លើសពីនេះទៀត គេសង្កេតឃើញថា សហគមន៍អន្តរជាតិ ហាក់បីដូចជាមានគោលជំហររួមមួយ ព្រមទាំងមានការសហការគ្នាយ៉ាងសកម្ម ដើម្បីប្រយុទ្ធប្រឆាំងនឹងភេរវកម្មតាមរយៈការអនុម័ត និងការអនុវត្តន៍យុទ្ធសាស្ត្រជាសកលប្រឆាំងភេរវកម្ម (UN Global Counter-Terrorism Strategy) ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងជាសាកលស្តីពីការប្រយុទ្ធប្រឆាំងភេរវកម្ម ជម្រើសគោល-នយោបាយមួយចំនួន ប្រហែលជាអាចយកទៅពិចារណា និងយកទៅពិភាក្សាដោយសមាជិកសភាកម្ពុជា នៅក្នុងកិច្ចប្រជុំពិភាក្សាស្តីពីភេរវកម្មនៃមហាសន្និបាតសហភាពអន្តរសភាលើកទី១៣៣ ជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីសន្តិភាព និងសន្តិសុខអន្តរជាតិ។ ជម្រើសគោលនយោបាយទាំងនោះរួមមាន៖

១) នៅក្នុងកម្រិតតំបន់ ប្រទេសកម្ពុជាអាចថែរក្សា និងពង្រឹងការគាំទ្ររបស់ខ្លួនទៅលើការអនុវត្តន៍នៃអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងភេរវកម្ម។ ការពង្រឹងការគាំទ្រចំពោះការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម

ប្រភពព័ត៌មានបើកទូលាយផ្សេងៗ និងបច្ចេកទេសស៊ើបអង្កេតតាមរយៈប្រព័ន្ធអ៊ិនធើណេត និង (៣) បណ្តុះបណ្តាល គ្រូបង្វឹក។ សូមស្វែងរកព័ត៌មានបន្ថែមតាមតំណភ្ជាប់នេះ៖ http://www.unodc.org/southeastasiaandpacific/en/cambodia/2013/09/ct/story.html

[23] UNODC. "Cambodian law enforcement officers become trainers to fight money laundering and the financing of terrorism." 2013. Accessed on 08 September, 2015. URL: http://www.unodc.org/southeastasiaandpacific/en/cambodia/2013/09/ct/story.html

[24] Ibid.

[25] PISCES គឺជាឧបករណ៍គ្រប់គ្រងព្រំដែនមួយ ដែលត្រូវបានតម្លើងដើម្បីជួយប្រឆាំងនឹងភេរវកម្ម។ វាត្រូវបានគេប្រើប្រាស់សម្រាប់បង្កើនសមត្ថភាពបញ្ជីត្រួតពិនិត្យតាមដានតាមរយៈការផ្តល់នូវប្រព័ន្ធ កំព្យូទ័រមួយដែលមានល្បឿនលឿនដើម្បីសម្រួលដល់ដំណើរការអន្តោប្រវេសន៍។ សូមស្វែងរកព័ត៌មានបន្ថែមតាមតំណភ្ជាប់នេះ៖ http://definitions.uslegal.com/p/personal-identification-secure-comparison-and-evaluation-system-pisces/

[26] U.S. Department of State. "Country Reports: East Asia and Pacific Overview." 2010.

នៅក្នុងក្របខ័ណ្ឌអាស៊ាននេះ នឹងចូលរួមចំណែក ក្នុងការធានាសន្តិសុខ និងសុវត្ថិភាពនៅក្នុងតំបន់ផងដែរ។

២) ជំរុញលើកទឹកចិត្តរាជរដ្ឋាភិបាល ក្នុងការចូលរួមចំណែកចែករំលែកព័ត៌មានយ៉ាងសកម្មពាក់ព័ន្ធភេរវជន ឬក្រុមភេរវជន ជាមួយនឹងរដ្ឋដែលជាសមាជិកអាស៊ាន ដែលជាផ្នែកមួយនៃអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងភេរវកម្ម។

៣) គាំទ្រវិធានការណ៍ទីបួននៃយុទ្ធសាស្ត្រជាសកលប្រឆាំងភេរវកម្ម (the UN Global Counter-Terrorism Strategy) ដែលពាក់ព័ន្ធនឹង "ធានាឲ្យមានការគោរពសិទ្ធិមនុស្សជាសកល និងនីតិរដ្ឋជាមូលដ្ឋានគ្រឹះក្នុងការប្រយុទ្ធប្រឆាំងភេរវកម្ម"។ ពាក់ព័ន្ធនឹងសេរីភាពបុគ្គល និងសិទ្ធិមនុស្ស វាមានភាពចាំបាច់ក្នុងការធានាតុល្យភាពរវាងឯកជនភាព និងភាពអាចទទួលយកបានរបស់រដ្ឋនូវទិន្នន័យឬព័ត៌មានដែលប្រមូលដោយ ស្ថាប័នរដ្ឋ និងក្រុមហ៊ុនឯកជននានា នៅក្នុងយុគសម័យបច្ចេកវិទ្យាកំពុងរីកចំរើនខ្លាំង ខណៈកំពុងប្រយុទ្ធប្រឆាំងនឹងភេរវកម្ម។ឯកជនភាពរបស់បុគ្គលម្នាក់អាចត្រូវបានរំលោភបំពានយ៉ាងងាយស្រួលផងដែរក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម។ ហេតុដូចនេះ ការធ្វើឲ្យមានតុល្យភាពរវាងសេរីភាពបុគ្គល និងការទទួលបានព័ត៌មានដែលប្រមូលដោយស្ថាប័នរដ្ឋ និងក្រុមហ៊ុនឯកជន គឺមានសារៈសំខាន់ដូចគ្នា ដើម្បីធានាថាសិទ្ធិមនុស្សត្រូវបានគោរពយ៉ាងពេញលេញ។

## គន្ថនិទ្ទេស


ASEAN. "ASEAN Convention on Counter Terrorism." 2014. Accessed on 07 September, 2015. URL: http://www.asean.org/news/item/asean-convention-on-counter-terrorism

Chheang Vannarith, and Chap Sotharith. "The Fight against International Terrorism: Cambodian Perspective." Working Paper No. 23, Phnom Penh, 2008.

CTITF. "Counter-Terrorism Implementation Task Force." Accessed on 01 September, 2015. URL: http://www.un.org/en/terrorism/ctitf/index.shtml

CTITF. "Entities." Access on 01 September, 2015. URL: http://www.un.org/en/terrorism/ctitf/entities.shtml

Sea Kosal. Measures to Eliminate International Terrorism. 2012. Accessed on 07 September, 2015. URL: http://papersmart.unmeetings.org/media/643762/Cambodia_Sea%20Kosal_statement.pdf;

UNACT. "International Legal Instruments." Accessed on September 02, 2015. URL: http://www.un.org/en/terrorism/instruments.shtml

United Nations. "The United Nations Global Counter-Terrorism Strategy." 2006. Accessed on 26 August, 2015. URL: http://www.un.org/en/terrorism/strategy-counter-terrorism.shtml

United Nations. "The United Nations Global Counter-Terrorism Strategy Review." 2012. Accessed on 02 September, 2015. URL: http://www.un.org/en/ga/search/view_doc.asp?symbol=A/RES/66/282

UNODC. "Cambodian law enforcement officers become trainers to fight money laundering and the financing of terrorism." 2013. Accessed on 08 September, 2015. URL: http://www.unodc.org/southeastasiaandpacific/en/cambodia/2013/09/ct/story.html

U.S. Department of State. "Country Reports: East Asia and Pacific Overview." 2010. Accessed on 02 September, 2015. URL: http://www.state.gov/j/ct/rls/crt/2010/170255.htm

Xiaohui, WU. "A Regional-Global Paradigm for Implementing the United Nations Global Counter-Terrorism Strategy." *Defence Against Terrorism Review* 2, no. 2 (2009): 83-98.

Marcel Furstenau. "Intelligence director warns of global spread of terrorism." *DW*, February 25, 2015. Accessed on 26 August, 2015. URL: http://www.dw.com/en/intelligence-director-warns-of-global-spread-of-terrorism/a-18281998

NATO. "Countering terrorism." September 01, 2015. Accessed on 09 September, 2015. URL: http://www.nato.int/cps/en/natohq/topics_77646.htm